# សេចក្ដីថ្លែងការណ៍

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាចេញផ្សាយនូវរបាយការណ៍ប្រចាំឆ្នាំស្ដីពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា

**រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សូមចេញផ្សាយនូវរបាយការណ៍ប្រចាំឆ្នាំស្ដីពី *ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅក្នុងប្រទេសកម្ពុជា* ដែលគម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា និងគម្រោងលើកកម្ពស់ និងការពារសេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យរួមគ្នាតាក់តែងឡើង។ លោកអ្នកអាចទាញយករបាយការណ៍តាមរយៈតំណភ្ជាប់នេះ សម្រាប់ភាសាខ្មែរ និងភាសាអង់គ្លេស។

របាយការណ៍នេះបង្ហាញពីទិដ្ឋភាពគ្រប់ជ្រុងជ្រោយនៃស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅក្នុងប្រទេសកម្ពុជា និងលទ្ធភាពរបស់សាធារណជនទូទៅក្នុងការអនុវត្តសិទ្ធិទាំងនេះ នៅក្នុងអំឡុងពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។ របាយការណ៍នេះក៏បង្ហាញទិន្នន័យសំខាន់ៗរួមមានការដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយ ចំនួន៤ ដោយរាជរដ្ឋាភិបាល អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សមួយចំនួនបានប្រឈមការបំភិតបំភ័យ និងយាយីតាមប្រព័ន្ធតុលាការ អ្នកសារព័ត៌មាន និងប្រជាពលរដ្ឋប្រឈមឧបសគ្គជាច្រើនក្នុងការទទួលព័ត៌មាន និងការដាក់កំហិតខ្លួនឯងនៅតែបន្តកើនឡើង។ ទិន្នន័យនេះក៏មានការរួមបញ្ចូលនូវសក្ខីកម្មពីអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សដែលរងនូវបញ្ហាប្រឈមនៅពេលដែលពួកគេអនុវត្តការងាររបស់ខ្លួនក្នុងបរិយាកាសមួយដែលកាន់តែមានភាពគ្រោះថ្នាក់ផងដែរ។

របាយការណ៍នេះ ក៏បង្ហាញពីការមិនបានអនុលោមយ៉ាងពេញលេញរបស់ច្បាប់ជាតិ ទៅនឹងច្បាប់និងបទដ្ឋានអន្តរជាតិ ដែលបានអនុញ្ញាតិឱ្យរដ្ឋាភិបាលកាត់បន្ថយ និងរឹតត្បិតសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន របស់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងប្រជាពលរដ្ឋ។

## អនុសាសន៍

នៅក្នុងបរិបទនេះ របាយការណ៍ក៏បានផ្ដល់អនុសាសន៍ជាច្រើនដល់រដ្ឋាភិបាល ដើម្បីឱ្យមានវិធានការដាក់លាក់ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមបទដ្ឋានច្បាប់អន្តរជាតិ ក្នុងការគោរព ការការពារ និងលើកកម្ពស់សេរី

ភាពខាងការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា។ ម.ស.ម.ក សូមដាក់ជូនអនុសាសន៍មួយចំនួនដល់អាជ្ញាធរ ដូចខាងក្រោម៖

- លុបចោល ឬធ្វើវិសោធនកម្មច្បាប់ដែលមានបញ្ហាមួយចំនួនដូចជា អនុក្រឹត្យស្ដីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ បទប្រមាថអង្គព្រះមហាក្សត្រ ឬច្បាប់ស្ដីការគ្រប់គ្រងប្រទេសជាតិក្នុងគ្រាអាសន្ន ដើម្បីធានាថាសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មានត្រូវបានការពារ។
- ដោះលែង ទម្លាក់ការចោទប្រកាន់ និងបញ្ឈប់រាល់ការយាយីតាមប្រព័ន្ធតុលាការ លើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដើម្បីឱ្យពួកគាត់អាចអនុវត្តសកម្មភាពស្របច្បាប់ដោយសេរី គ្មានភាពភ័យខ្លាច ឬឧបសគ្គរាំង។
- បញ្ចប់និទណ្ឌភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សដោយស៊ើបអង្កេតយ៉ាងហ្មត់ចត់ និងឯករាជ្យ និងនាំយកជនល្មើសទៅកាត់ទោស ឬ
- ធានាថាគ្រប់ស្ថាប័នរដ្ឋាភិបាល ស្ថាប័នសាធារណៈ និងស្ថាប័នឯកជនដែលបំពេញមុខងារសាធារណៈទាំងអស់ ប្រកាន់ខ្ជាប់នូវគោលការណ៍នៃការបង្ហាញព័ត៌មានជាអតិបរមា និងយល់ព្រមរាល់សំណើសុំបង្ហាញព័ត៌មាន ជាពិសេសសំណើពីអ្នកសារព័ត៌មានស្នើសុំទិន្នន័យដែលគ្រប់គ្រងដោយរដ្ឋាភិបាល ដើម្បីឱ្យព័ត៌មានមានសារៈសំខាន់ចំពោះប្រយោជន៍សាធារណៈអាចផ្សព្វផ្សាយបានដោយសេរីនៅក្នុងប្រទេស និងបង្កើនតម្លាភាព និងគណនេយ្យភាពចំពោះសកម្មភាពរដ្ឋាភិបាល។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួលគម្រោងការលើកកម្ពស់ និងការពារសេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ នៃ ម.ស.ម.ក លោក ហួន ផន តាមរយៈអ៊ីម៉ែល**

phorn@cchrcambodia.org **ឬ ០៧០ ៧៥៧ ៨៨៤ ៕**

<u>ចប់</u>

## បណ្ណាធិការ៖

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា( "ម.ស.ម.ក" )បានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្ដូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្ដាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និងជាសមាជិក OECD Watch ៕

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រ៊ីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។